កិច្ចសម្ភាសរបស់បងស្រី ដួង រេចរ៉ា

ក៖ អ្នកសម្ភាសនឈ្មោះហេង សុជីវី ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ ដួង រេចរ៉ា

<u>ការសង្ខេបកិច្ចសម្ភាសរបស់បងស្រី ដួង រេចរ៉ា</u>

បងស្រីដួង រេចរ៉ា គាត់មានអាយុ៣៨ឆ្នាំ កើតនៅខែផល្គុន ឆ្នាំ១៩៨០ ក្នុងឆ្នាំ២០១៨។
គាត់មានទីលំនៅនាពេលបច្ចុប្បន្ននៅច្បារអំពៅ រាជធានីភ្នំពេញ។
គាត់មានកូន៣នាក់ស្រី២នាក់ និង ប្រុស១។
គាត់បានរៀបការជាមួយស្វាមីជាជនជាតិខ្មែរភាគតិច
ហើយបងស្រីជាខ្មែរកម្ពុជាក្រោម។

ក៖ បងជាដំបូងជម្រាបសួរបង!

ខ៖ ចាសជម្រាបសួរ!

ក៖
ចាសបងនៅថ្ងៃនេះខ្ញុំមានឱកាសដើម្បីមកសម្ភាសបងហើយថ្ងៃសម្ភាសគឺជាថ្ងៃទី ២៥ខែ៨ឆ្នាំ២០១៨ ហើយខ្ញុំមានឈ្មោះថា ហេង សុជីវី គឺជាអ្នកសម្ភាស ហើយចុះបងវិញ តើបងមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំនៅក្នុងអត្តសញ្ញាណប័ណ្ណមានឈ្មោះថា ដួង រេចរ៉ា
តែនៅក្រៅគេហៅថាស្រីៗចឹងណា។

ក៖ ចាសបង ឈ្មោះហ្នឹងត្រូវជាមួយនឹងអត្តសញ្ញាណប័ណ្ណអត់?

ខ៖ ឈ្មោះ ដួង រេចរ៉ា ហ្នឹងត្រូវ។

ក៖ ចាស! បងហើយអី! បងដូចជាឈ្មោះទាំងនាមត្រកូលអីទាំងអស់បងហ៎ ដួង រេចរ៉ា ហ្នឹង តទាំងនាមត្រកូល ទាំងឈ្មោះហៅរបស់បង?

ខ៖ បើនៅក្នុងគ្រួសារខ្ញុំគេហៅឈ្មោះចឹង។ គ្រួសារម៉ែក្មេកខ្ញុំ
ឬនថ្លៃអីចឹងគេហៅរេចរ៉ាៗ ចឹងបើថានៅក្រៅចឹង ខាងនេះចឹង ខ្ញុំមកហ្នឹង
គេហៅថាអាស្រីៗទេ។

ក៖ ចឹង?

ខ៖ ចាស!

ក៖ ចាស! ហើយបងនៅឆ្នាំហ្នឹង តើបងមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំ៣៨ហើយ! ខ្ញុំកើតនៅក្នុងឆ្នាំ១៩៨០។

ក៖ បងកើតនៅក្នុងថ្ងៃខែណាដែរ?

ខ៖ ខ្ញុំកើតនៅក្នុងថ្ងៃខែផល្គុន តែខ្ញុំអត់ដឹងថ្ងៃណាដែរ ដឹងថានៅខែផល្គុន។

ក៖ ចាស! ហើយកាលណុងដូចជាឪពុកម្តាយបងបានដាក់ឈ្មោះហ្នឹង ហើយ ប្រាប់បងពីថ្ងៃខែឆ្នាំកំណើតហ្នឹងបងហ៎?

ខ៖ អឹម...កើតហើយ គាត់ទៅចោលទៅ។

ក៖ ឪពុកម្តាយបងគាត់មានឈ្មោះអីដែរបង?

ខ៖ ឈ្មោះតាមគេហៅវៀតណាមចឹងណា។ តែគ្រាន់ថាឈ្មោះខ្ញុំពេលខ្លះ
កើតមកដូចថាអ៊ុនៅជីតផ្ទះហ្នឹង គាត់ស្រលាញ់ឈ្មោះហ្នឹង ចឹងចេះតែដាក់ចឹងទៅ
តែនៅស្រុករបស់ខ្ញុំគេហៅថាស្រីៗចឹងណា។

ក៖ ចាស!

ខ៖ តែខ្ញុំមកដល់ភ្នំពេញ ក៏ខ្ញុំនៅតែឈ្មោះចឹងដែរ ហើយនៅក្នុងអត្តសញ្ញាណប័ណ្ណ
នៅក្នុងសៀវភៅគ្រួសារអីខ្ញុំក៏ដាក់ចឹងដែរ។

ក៖ ចាស!បងទីលំនៅស្រុកកំណើតរបស់បងនៅឯណាដែរ?

ខ៖ ខ្ញុំនៅកម្ពុជាក្រោម! នៅខេត្តឃ្លាំង តែខ្ញុំបានមករកនៅស្រុកភ្នំពេញហ្នឹង ខ្ញុំ
មានប្តីនៅច្បារអំពៅ។

ក៖ ចាស!

ខ៖ ចាស!

ក៏
ហើយទៅអី...នៅសព្វថ្ងៃបានមកនៅឯច្បារអំពៅហើយបានមករស់នៅជាមួយនឹងស្វាមីរបស់បងនៅឯខាងច្បារអំពៅហ្នឹងហ៎ាបង?
ខ៏ ចាស!
ក៏ ហើយបងសព្វថ្ងៃមានកូនប៉ុន្មាននាក់?
ខ៏ កូន ៣នាក់ ស្រី២នាក់ ប្រុស១។ តែដូចថាឥឡូវថ្ងៃហ្នឹង
ថ្ងៃឡើងយកទៅរៀនអីចឹងហ្នា ហើយខ្ញុំព្រឹកឡើងមកលក់ចឹង
ល្ងាចឡើងទៅផ្ទះហើយ ប្តីមកយកទៅផ្ទះ។
ក៏ ចាស ចឹងសព្វថ្ងៃបងលក់អីគេខ្លះដែរ?
ខ៏ នេះលក់កំប៉ៃកកំប៉ុកហ្នឹង។ លក់ទានធ្លាបអីចឹងណ៎ា ដូចថាលក់អោយយាយៗ
អ្នកគេមកបិណ្ឌមកនេះចឹង ហើយអ្នកដែលគេមកស្រោចទឹកអីចឹង គេ
ជួយទិញជួយអ៊ីចឹងទៅ។ ថ្ងៃណាដាច់ៗ ថ្ងៃណាមិនដាច់នេះដែរ។
ថ្ងៃហ្នឹងគ្មានលក់បានណា! បានផ្ការ៉ាអីបន្ទ្ចិចបន្ទ្ចចឹងណ៎ា។
ក៏ ចាស! ហើយបងហើយអី!ការងារហ្នឹង
បងប្រកបមុខរបរនេះបានយូរប៉ុណ្ណាដែរ?
ខ៏ ខ្ញុំទើបតែប្រកបទេ! ព្រោះអីពីមុនកន្លែងនេះ កន្លែងម៉ែខ្ញុំ ឥឡូវគាត់
ឈប់លក់ ហើយគាត់មានពីរកន្លែងចឹង គាត់លក់នៅមុខ ហើយកន្លែងហ្នឹង
ខ្ញុំឃើញគេទុកចោលចឹង ខ្ញុំក៏មកលក់នៅនេះទោ
ក៏អោយគេថាពេលដែលមកលក់ចឹងម្ល៉ាយចេះតែសួរចឹងហ្នា ថាលក់...អត់ដែល
ឃើញមកលក់ទេអី? ចឹងហ្នា!
ក៏ ចាស!
ខ៏ ដល់ពេលនៅថ្ងៃសីលបានមកលក់!ក្រៅពីថ្ងៃសីលអត់មកលក់នោះទេ។
ក៏ ចាស!
ខ៏ ហើយចឹងទៅ ម្ល៉ាយមកថ្ងៃសីលគេសួរហើយ គាត់ថាអត់ឃើញអីចឹងហ្នា
ដល់ហើយទៅខ្ញុំឃើញចឹង ខ្ញុំក៏ប្រាប់ម៉ែខ្ញុំថា កន្លែងហ្នឹងខ្ញុំសុំលក់
ខាងក្រោយហ្នឹងវិញ ម៉ែខ្ញុំថាលក់អីលក់ទៅគាត់មិនហាមឃាត់ទេ។
ក៏ ហ៊ីស!
ខ៏ ហ្នឹងហើយចាស!
ក៏ ត្រូវហើយបង តមុខរបរពីម៉ាក់ទៀត។
ខ៏ ចាស!
ក៏ ហើយចឹងកាលតើជំនាន់មុនម៉ាក់របស់បងគាត់មានឈ្មោះអីដែរបង?
ខ៏ គាត់ឈ្មោះ ឡុង សារ៉ាន!
ក៏ ចុះឪពុករបស់បងវិញ?
ខ៏ ឪពុកខ្ញុំនៅកោះកុង!
ក៏ ចាស!
ខ៏ តែគាត់ឈ្មោះថាតាមនៅនេះ...ឈ្មោះតាមខ្មែរកម្ពុជាក្រោមហ្នឹង គេដាក់នេះ
អ៊ី...តែខ្ញុំមិនដែលដឹងត្រកូលគាត់ឈ្មោះអី។
ក៏ ចាស!
ខ៏ ព្រោះអីគាត់ពេលដូចថា...គាត់នេះម៉ែខ្ញុំហើយដូចថាពោះធំគាត់ទៅចឹង
ចោលចឹង! ហ្នឹងហើយ អត់ដឹងត្រកូលម៉េចទេ តែថាមុខមាត់ឃើញស្គាល់ តែ
មុខមាត់គាត់ឃើញស្គាល់ មួយ រយ:ជាងប្រហែល១០ឆ្នាំហ្នឹង។ ទើប
ស្គាល់គាត់ហ្នឹង ស្គាល់មុខពិត តាំងពីតូចដល់ធំអត់ដែលស្គាល់ទេ។ គេ
ថានឹកឃើញថា តូចចិត្តខ្លួនឯងចឹងថាគេមានឪម៉ែចឹងហ្នា
ហើយយើងគ្មានចឹងចង់រកឪចឹងហ្នា។
ក៏ ចាស!
ខ៏ ហើយខំទៅរកគាត់នៅដល់កោះកុងអីចឹង។
ក៏ ហើយចឹងបងរកឃើញអត់?

ខ៖ ឃើញ!
ក៖ ហើយគាត់មកវិញទេ?
ខ៖ អត់ទេ! គាត់មានកូនមានប្រពន្ធទៀតទៅ។ អើអាហ្នឹង!
គាត់មានប្រពន្ធមានកូន ម៉ែយើងក៏មានប្ដីទៀតទៅ យើងទៅបំបែកបំបាក់អីគេ។ អាហ្នឹងដូចថាវាមិននិស្ស័យជាមួយគ្នាចឹងហ្នឹង បើសិនមាននិស្ស័យប្ដីប្រពន្ធជួបគ្នាដល់ចាស់កោងខ្នងហើយ។ អានេះដូចថាស្រលាញ់បានតែត្រឹមហ្នឹងចឹងណា កម្មពៀរគាត់បានតែត្រឹមហ្នឹងចឹង។ ចឹងដូចថាឥឡូវយើងអូសទាញ គាត់មកនៅជាមួយម៉ែចឹង អាហ្នឹងយើងក៏ពិបាកណា។ គាត់ក៏មានប្រពន្ធ មានកូនហើយចឹង យើងធ្វើ ចឹងវាមិនកើតណា។
ក៖ ចាស! បងកាលពីមុន បងចងចាំឪពុកម្ដាយបងគាត់ជាមនុស្សបែបណាដែរបង?
ខ៖ ម្ដាយខ្ញុំគឺថាតាយាយខ្ញុំគាត់ស្រលាញ់ចឹង ដូចថាមជ្ឈតាម៉ែឪស្រលាញ់ពេកគឺខូចអ៊ីបន្ដិចបន្ដួចហើយ។
ក៖ ខូចម៉េចទៅ? បានចិត្ត?
ខ៖ កាលនៅពីក្មេង គាត់ដើរលេង ដើរអីចឹងហ្នា ហើយកាលណុងគាត់អាយុ ១៦ទៅ១៧ ក៏ចេះតែដើរលេងមានសង្សារមានអីចឹងហ្នា។ ដល់ពេលហើយទៅយាយខ្ញុំគាត់ស្រឡាញ់ចឹង តាខ្ញុំគាត់ស្រឡាញ់ចឹង និយាយមិនស្ដាប់អីចឹង។ ចាស់ៗពីដើម អត់ចេះរៃកូនអីដូចឥឡូវទេ ដោយសារតែនេះទៅ...
ក៖ ចាស! អូ! ហើយកាលហ្នឹងគាត់មានរបរអីចិញ្ចឹមជីវិតដែរបង?
ខ៖ ពីមុនយាយនៅស្រុកកម្ពុជាក្រោមហ្នឹង យាយគាត់រត់ទូកដ។ ខ្មែរកម្ពុជាក្រោមគេហៅថារត់ទូកដហ្ន៎! ហើយអត់មានម៉ាស៊ីនមានអីទេ យើងមានច្រវាហ្នឹងចែវអ៊ុំគេវទៅថា ពីដើមចឹងមួយកាក់ពីរកាក់អីចឹង គេនិយាយចឹងហ្នា។
ក៖ ចាស!
ខ៖ តែអាហ្នឹងអត់ទាន់ទេ តែយាយខ្ញុំគាត់និយាយប្រវត្ដិប្រាប់ចឹងហ្នា។
ក៖ ចាសបង! ហើយទៅលោកយាយលោកតារបស់បងទាំងខាងឪពុកខាងម្ដាយគាត់ឈ្មោះអីដែរបង?
ខ៖ លោកតាខាងឪពុកក៏ខ្ញុំអត់ដែលស្គាល់ដែរ។ បើថាខាង...ស្គាល់តែយាយទេ ព្រោះអីយាយខាងឪពុកហ្នឹងឧស្សាហ៍ទៅលេងខ្ញុំ ពីតូចអីចឹង ឧស្សាហ៍ទៅរកអីចឹងហ្នា។ ខ្ញុំស្គាល់ស្រុក ស្គាល់អីចឹង ស្គាល់ឈ្មោះ ហើយបើថាតាខាងឪពុកអត់ដែលស្គាល់ទេ។
ក៖ ចាស!
ខ៖ តែមាមីងអីស្គាល់ទាំងអស់។ ចាស!
ក៖ ចឹងកាលពីសម័យមុខណុងបងធ្លាប់ឪពុកម្ដាយឬក៏អ្នកណាដែលប្រាប់បងអំពីជីវិតជីការបស់បង ដូចថាគាត់មានចរិតលក្ខណៈបែបណាអីដែរ?
ខ៖ គាត់ដូចថា អ្នកខ្លះគេនិយាយថាមកពីអ៊ុំខ្ញុំអត់អោយម៉ែ ខ្ញុំយកអីចឹងចេះចុសអីចឹងហ្នា ហើយគាត់ខឹងចឹង គាត់ទៅៗ ទៅចោលម្ដាយខ្ញុំ ពោះធំពោះអីចឹងណា។
ក៖ ចាសបង! ហើយកាលសម័យណុងបង រៀនដល់កម្រិតណាដែរ?
ខ៖ ខ្ញុំសម័យណុងមានមរៀនមានអី គ្រាន់តែថាទៅរៀនថ្នាក់ទី១អី គ្រាប់តែបានថា បានទៅសាលាលេងហ្នឹង ជាតិៗពីផ្ទះ ពីក្មេងប៉ុណ្ណឹង។
ក៖ ចាស! ហើយចឹងបងអាចចេះសរសេរ ចេះអានភាសាខ្មែរយើងបានល្អដែរឬទេ?
ខ៖ ខ្ញុំអក្សរខ្មែរខ្ញុំអត់ចេះផង។ បើថាសរសេរចឹង ខ្ញុំមើលតាមសរសេរបានហើយបើថាអោយខ្ញុំអាន ឱ្យខ្ញុំថាគេអានហើយអោយខ្ញុំសរសេរ ខ្ញុំអត់ចេះផង។
ក៖ ហើយសម្រាប់ភាសាផ្សេងពីខ្មែរ បងចេះភាសាអីទៀត?

ខ៖ ខ្ញុំចេះ ដូចថាអក្សរវៀតណាមចឹង ខ្ញុំចេះខ្លះៗ ចេះបានដូចថា
យើងទៅតាមផ្លូវចឹង រង្វេងអីយើងមើលទៅ តាមផ្លូវទៅណា ក៏ន្លែងហ្នឹងគេហៅ
អីចឹង បាន។
ក៖ចាស!
ខ៖ហ្នឹងហើយ!
ក៖
កាលណុងបងចេះភាសាវៀតណាមបានតាមរយ:ឪពុកម្តាយដីដូនដីតាឬក៏រៀនប
ង?
ខ៖ អើ...រៀនអក្សរវៀតណាម ហើយនៅស្រុក
ខ្ញុំគេច្រើនតែនិយាយវៀតណាមផងដែរហ្នឹង។
ក៖ ចាស! បានចេះពីគេពីឯងមក តែអត់បានចូល
សាលារៀនភាសាវៀតណាមបងហ៎?
ខ៖ នៅស្រុកខ្ញុំ គេរៀនអក្សរវៀតណាម យូរៗទៅយើងចេះហើយ
យើងនិយាយតាមគេចឹង។
ក៖ ហើយបងរាល់ថ្ងៃ ជួនកាលពេលមានកម្មវិធីអី បងទៅស្រុកដែរឬអត់?
ខ៖ ថាចង់ទៅដែរ តែយើងវាអត់មានលុយមានកាក់អីចឹង ទៅថារាល់តែមួយថ្ងៃ
ស៊ីមួយថ្ងៃទេ បងអើយ។ ចេះតែទ្រាំទៅ ធ្វើម៉េច។ បើយើងមិនរក វាអត់។
ហើយបើមិនរក យើងមានតែខ្ចីលុយគេ។
ហើយបើយើងគ្មានមុខរបរចឹងមាននរណាគេឱ្យខ្ចីរកស៊ីអត់រកអី។
ចឹងមានតែយើងខំប្រឹងទៅ ថាតើអើ! ជួនកាលអង្គបាន១ឆ្នាំៗ រកទៅ
ក៏បានដែរ។
ក៖ ចឹងកាលពីមុនក្នុងជីវិតបងធ្លាប់ឆ្លងកាត់ការងារអី
ខ្លះដើម្បីរកកម្រៃចិញ្ចឹមជីវិត?
ខ៖ តែនិយាយថាពីមុនហ្នា ជីវិតខ្ញុំកម្សត់ណាស់ នៅស្រុកខ្ញុំយប់ឡើងជួនកាល
អ៊ុវ៉ែមិនឱ្យនៅផ្ទះអីចឹង ទៅដេកផ្លូវខ្នោច។
ក៖ អូ! មានចឹងដែរ?
ខ៖ មានតើ! ទៅដេកផ្លូវខ្នោច ផ្លូវខ្នោចលោកយាយទួតខ្លួនឯង។
ក៖ អូ!
ខ៖ ដូចថាគាត់យកទៅកប់ក្នុងវាលស្រែ
វាលស្រែហ្នាហើយជួនកាលខ្ញុំមិនដឹងទៅណាចឹង ទៅដេកក្នុងវាលស្រែចឹង
ដេកនៅលើផ្លូវខ្នោចចឹង ហើយចេះតែនឹកឃើញថាហ៊ីម...នៅគេចេះតែ
រ៉ែដំធ្វើបាបចឹង ចេះតែតាមដំណើរ បានឡើងមកស្រុកខ្មែរ។
ក៖ ចាស!
ខ៖ ប៉ុន្តែយើងរកចឹង មួយថ្ងៃកាត់មួយថ្ងៃកោរ បើសិនថាដូចថ្ងៃហ្នឹងហ្នាស
មិនទាន់លក់បានស្អីផងនេះ បានផ្ទាបន្ទីចបន្ទួច
ដូចថាយើងបានចំណេញផ្ទាបន្ទីចបន្ទួចចឹងទៅ ក្រាន់តែមួយរស់ទៀតទៅ
ថ្លៃម៉ូតូឌុបបើថានេះ ថាថ្លៃសុំងទៅផ្ទះវិញទៅ។
ក៖ ចាស!
ខ៖ ហើយថ្ងៃណាចឹងទៅភ្ជៀរមកចឹង ថ្ងៃណាដាច់ៗចឹងទៅបានអើយ!
៤ទៅ១០ម៉ឺនអីចឹងដែរ។ ថ្ងៃណាអត់ ហើយបើថាអត់ពេកទៅ! វាមាន
១ម៉ឺនទៅ២ម៉ឺនទៅ វាមិនអត់ពេកចឹងហ្នា។
ក៖ ចាសបង!
ខ៖ ចាស!
ក៖ ប៉ុន្តែដូចជាបងមានមុខរបរអ្វីក្រៅពីហ្នឹងទេកាលពីមុនៗមកបង?
ខ៖ ពីមុនៗខ្ញុំ ដើរលក់នំ ដើរ...មុនដំបូងខ្ញុំលក់ប៉ាតេលក់អីចឹង។ ខ្ញុំចេះតែធ្វើ
ក្រប់ប៊ែបយ៉ាងចឹង លក់ប៉ាតេ ដល់ហើយទៅខ្ញុំឈប់លក់ឈប់អីចឹងទៅ!
ប៉ុន្ទានខែមកខ្ញុំទៅលក់នំម្តង លក់អានំពងទាហ្នឹង តែថៅកែគេនៅម្តុំផ្ទះខ្ញុំហ្នឹង

គេធ្វើបោះអោយយើងលក់អីចឹងហ្នា។ ប៉ុន្តែកាលណុងខ្ញុំបោះចូលតែ៩០០(រៀល)ទេ។ យើងលក់បាន១៥០០(រៀល)២០០០(រៀល)ចឹងទៅ
យើងចំណេញបានដូចថា២ម៉ឺនទៅ៣ទៅ៤ម៉ឺនចឹងដែរ។ ឥឡូវគេឡើងថ្លៃ
មួយ១៣០០(រៀល) ខ្ញុំលក់ចេញបាន១៥០០(រៀល)ខ្ញុំបានអីស៊ុ។
ក: ហឹម! ចាស! ដល់ពេលចឹងជីវិតរបស់បងតាំងពីមុនមកដល់ឥឡូវនេះ
បងគិតថាបងមានការផ្លាស់ប្តូរអីគេខ្លះដែរបង?
ខ: ខ្ញុំគិតថាមិនមែនផ្លាស់ប្តូរទេ ចេះតែតស៊ូចឹងទៅ គេហៅលាងបានក៏លាង
គេហៅលាងឆ្នាំងក៏លាងដែរ អោយតែមានលុយអោយកូនស៊ី (សើច)។
ក: កូនរបស់បងប៉ុន្មាននាក់ហើយបង?
ខ: បីនាក់។
ក: គាត់ឈ្មោះអីខ្លះ បង?
ខ: អឺ...សយ រតនា សយ នីសា សយ ប៊ុនលាប។
ក: គាត់រៀនដល់ណាហើយបង?
ខ: អឺ... កូនខ្ញុំមីធ្យងហ្នឹង អឺ...ឥឡូវចូលវិទ្យាល័យហើយ ថ្នាក់ទី៧។
ក: វិទ្យាល័យនៅណាដែរបង?
ខ: នៅធ្យារអំពៅ។
ក: ចាស! ហើយក្រុមគ្រួសាបង បងប្រុសត្រូវជាស្វាមីបងគាត់ឈ្មោះអីដែរ?
ខ: គាត់ឈ្មោះ សុំង សុភាព។
ក: គាត់ខ្មែរកម្ពុជាក្រោមដែរ?
ខ: ខ្មែរលើ។ ខ្មែរនៅហ្នឹងម៉ង។
ក: ស្រុកកំណើតគាត់នៅណាបង?
ខ:ថានៅពញ្ញាឦ ទៅកំពង់ចាមហ្នាស។
ក: ចាសបង ហើយទៅចឹង បងមានបំណងមានប្រាថ្នាអីសម្រាប់កូនរបស់បងទេបង?
ខ: ខ្ញុំដូចជាមួយប្តីខ្ញុំចឹងទៅ ខ្ញុំថាខ្ញុំរាល់ ខ្ញុំចិញ្ចឹមតែខ្លួនទេ។
អត់មានអាចចិញ្ចឹមចិត្តកូនទេ ដូចថាឥឡូវកូនធំឡើង ចិត្តវាម៉េចនេះម៉េច
អាហ្នឹងខ្លួនរបស់វា វាមិនចេះស្រលាញ់ខ្លួនកំខ្ញុំអត់ដឹងធ្វើម៉េចដែរ។
ពេលវាទៅរៀន វាអត់ទៅរៀនក៏ខ្ញុំមើលអត់ឃើញដែរ ព្រោះខ្ញុំមករកស៊ីមកលក់ដូរ
ក: ចាស!
ខ: ហើយប្តីខ្ញុំថាឥឡូវប្រើងហ្នាស រាល់តែថ្ងៃគឺយប់ឡើងចឹង ខ្ញុំពីរនាក់ប្តីខ្ញុំចឹងដឹកនាំកូនហ្នា ម៉ាក់ប៉ាខំប្រើងហ្នា ដើម្បីអ្នកណា? ដើម្បីកូនប្រើងរៀន
ចេះទៅចំណេះរបស់កូន គ្មានអី គ្មានកេរ្តិ៍ត្នាអីចែកអោយទេ
ត្រាន់តែថាឱ្យកូនចេះទៅ ចំណេះខ្លួនឯងទៅណ៎ា អនាគតខ្លួនឯង ហើយខ្ញុំចាស់បន្ដិចទៀត បើសិនកូនមិនចិញ្ចឹមទេ យើងនាំគ្នាទៅនៅវត្ត។ (សើច)
ហ្នឹងហើយ ប្តីប្រពន្ធ។
ក: ចាស! ចឹងកាលណុងបងស្រឡាញ់គ្នាឬ ឪពុកម្តាយជាអ្នកទុកដាក់អោយបង?
ខ: ស្រលាញ់គ្នា!
ក: ចាស! រយៈពេលប៉ុន្មានដែរ បានបងបានរៀបការបង?
ខ: អត់បានការផង! ចាស!
ក: ចឹងបងស្រលាញ់គ្នាយូរហើយណាបង?
ខ: ចាស! ខ្ញុំស្រលាញ់គ្នាចឹង ហើយបានថារស់នៅជាមួយគ្នាចឹង ដូចថាដំបូងគេក៏មិនសូវពេញចិត្តយើងទេណ៎ា ហើយដល់ហើយទៅដូចថាតស៊ូប្តីប្រពន្ធ
ទៅជួលផ្ទះជួលអីនៅ ផ្ទះគេ ចឹងមួយថ្ងៃមួយរៀល អោយថ្ងៃផ្ទះគេចឹងហ្នា។
ក: ហើយទៅកាលហ្នឹងដូចជាបងប្រុសគាត់ធ្វើមុខរបរអ្វីដែរ?
ខ: ពីមុនផ្ទះឪក្មេកខ្ញុំគាត់ធ្វើព្រះ ឆ្លាក់ព្រះហ្នោះ។
ក: ឆ្លាក់រូបព្រះ?

ខ៖ ចាស! តែ ឥឡូវនេះគាត់ចាស់មុខរបរហ្នឹងគាត់ឈប់លក់ហើយ! តែអ្នកផ្លែខ្ញុំ
ម៉ែក្មេកខ្ញុំឥឡូវគាត់ក៏ចាស់ដែរ! គាត់អាយុ៦០ជាងហើយ តែដូចថាអ្នកផ្លែខ្ញុំឥឡូវ
គេបើកលក់ទូរសព្ទ៍ទូរអីមុខផ្ទះចឹង លក់ចាប់ហួយអីបន្តិចបន្តួច
ធ្វើសក់ធ្វើអីចឹងណា។
ក៖ ចាស!
ខ៖ ត្រាន់បានអង្ក ទិញអង្ករចិញ្ចឹមម្តាយចឹង!។
ក៖ ចាសបង!
ខ៖ កាលមុនឪក្មេកខ្ញុំគាត់កាន់ការ ឥឡូវអស់ពីគាត់ទៅហើយមម៉ែក្មេកខ្ញុំ
គាត់មិនសូវនេះអីគាត់ស្រពីងស្រពឹម គាត់ចាស់ហើយហ្នឹង ចឹងអោយកូនលក់
រកស៊ីចិញ្ចឹមគាត់វិញទៅ។
ក៖ បងហើយទៅដូចជាពេលដែលបងស្រលាញ់ជាមួយបងប្រុស
បងអាចប្រាប់បានទេមុនដំបូងបងជួបគាត់នៅណាដែរ?
ខ៖ ខ្ញុំជួបគាត់នៅសូរិយា (ផ្សារទំនើប)។
ក៖ (សើច!ហេសៗ!) ហើយម៉េចទៅពេលណុង?
ខ៖ គាត់ដូចថា គាត់ឃើញខ្ញុំចឹងគាត់ថាស្រលាញ់ ហើយគាត់ចេះតែតាមខ្ញុំចឹង
ហើយដល់ហើយទៅ ពួកម៉ាកខ្ញុំវាចេះតែនិយាយថាប្តីខ្ញុំមុខមិនស្អាតទេ
អាក្រក់ណាស់ តែត្រាន់ថាខ្ញុំគិតថាបើស្អាតពេកក៏មិនដឹងយកទៅធ្វើអី។ អត់ទេ
មែនតើ ហើយពួកម៉ាកខ្ញុំគេថា៖ “ហ៊ីស! ដូចមួយពិភពលោកនេះដូចគ្មានប្រុស។”
ក៖ ហ៊ីស!
ខ៖ តែខ្ញុំថា ហ៊ីស! អាយើងស្រលាញ់គេ យើងទឹកភ្នែកទៅ បើគេស្រលាញ់យើង
យើង ស្ដួល។
ក៖ ចាស! ហើយទៅពេលណុងដូចជាបងស្រលាញ់បងប្រុសដោយសារអីដែរ?
ខ៖ នឹកឃើញថាគ្នាក៏ប្រវត្តិកម្សត់ជាងខ្ញុំទៅទៀត ដេកក្រៅផ្ទះដែរ
ដូចថាឪពុកម្តាយអត់សូវយកការចិត្តទុកដាក់អីចឹងដែរហ្នា ដូចថាគ្នាកម្សត់
ដូចថាប្រវត្តិគ្នាក៏ជូរចត់ដែរ ដូចថានិយាយរួមដូចថាអត់មានទីលំនៅពិតប្រាដក
ចឹងដូចថាដើរទៅធ្វើការដូរបាយ ទៅដូចថាទៅជួយដឹកសុំងដឹកអីអោយ
មីងចឹងទៅ មីងគាត់អោយ២ទៅ៣ពាន់ចាយចឹងទៅ។
ហើយជួយធ្លាក់ព្រះឱ្យឪក្មេកចឹងទៅ គាត់អោយ៤ទៅ៥រៀលអីបានចាយ
ចឹងទៅណ៎ា។
ណ៎ា។
ក៖ ចាសបង!
ខ៖ ហើយបងអ្នកនីដូនមួយចេះតែហៅប្រើនេះប្រើនោះ ទៅ ប្តីខ្ញុំហៅធ្វើអីក៏ធ្វើដែរ
ឧស្សាហ៍ណាស់ ហើយបងអ្នកហ្នា អោយតែបងអ្នកហៅទៅណាក៏ទៅដែរ។
ក៖ ចាស!
ខ៖ ហើយស្លូតណាស់!
ក៖ គាត់អត់ចេះផឹកចេះអីបងហ្នោះ?
ខ៖អត់ចេះទាំងអស់!
ក៖ ចាសហើយទៅបន្ទាប់មកទៀតបងកាលពីសម័យកាលដែលបងបាន
ឆ្លងប្រទះមានគ្រួសារមានអីមកហើយហ្នឹង
បងគិតថាជីវិតបងមានការលំបាកអីគេខ្លះដែលបងចងចាំអត់ភ្លេចសោះឡើយ
ហ្នា?
ខ៖ អឺម! កាលពីមុនខ្ញុំថា ខ្ញុំមើលទៅពិបាក តែមើលគេពិបាកជាងខ្ញុំទៀត។
ក៖ ហឹម!
ខ៖ អ្នកខ្លះទៅដូចថាមានប្តីមានអីចឹងដូចថាប្តីធ្វើបាបធ្វើអីចឹងហ្នា
អ្នកខ្លះទៅគេមានសំណាង ចឹង ហើយអ្នកខ្លះទៀតមធ្យមចឹងទៅ ហើយដល់
ទៅយើងឃើញគេលំបាកចឹងវាដូចមើលគេទៅគេលំបាកជាងយើងទៀត។
ក៖ ហឹម!ចាសបង!

ខ៖ តែខ្ញុំដល់ទៅចឹងទៅ ឃើញលំបាកអីចឹងចេះតែអាណិតគេ តែយើងក៏
គ្មានសមត្ថភាពជួយគេបានត្រឹមតែអាណិត។
ក៖ ហឹម! ចាសតែសម្រាប់បងខ្លួនឯង បងមាន...
ខ៖ ខំប្រឹងដែរ គិតថាអង្គាល់មានលុយទិញផ្ទះទិញដីនៅដូចគេដូចឯងចឹងហ្នា
ហើយដូចថាដីអីបើសិនយើងមានលុយអីចឹងទិញដីនៅ
ធ្វើផ្ទះធ្វើអីនៅម៉ាលូមអីចឹង ហើយយើងទុកដីទុកអីដាំដូចថា
ដំណាំធម្មជាតិអីចឹងណ៎ា។
ក៖ ហឹម!
ខ៖ គិតចឹងមិនមែនថាគិតចង់បានស្អីលោភលន់ចង់ធ្វើជាឧកញ៉ាអីជំទាវអី
អត់ទេ។ ដូចថាបានសុំតែដូចថាមានលុយមានអីយើងទិញដីទិញអីចឹង
នៅផ្ទះហើយប្តីខ្ញុំថាបើថាមានលុយមានអីចឹង ទិញដីទិញអី មានផ្ទះចឹងលក់
ចាបហួយចឹង លក់ទឹកកកអានាម័យលក់អីចឹង ប្តីខ្ញុំគាត់គិតអញ្ចេក។
ក៖ ចាស!
ខ៖ចាស! អត់មានថាគិតស្រមើស្រម៉ៃដូចថាចង់បានវីឡាអីខ្ពស់ដូចគេអត់ទេណ៎ា
ឃើញគ្រាន់ថាឃើញគេមានផ្ទះមានអីចឹង មើលគេទៅចឹង
រាងតូចចិត្តខ្លួនឯងដែរចឹង។
ក៖ បងកាលពីសម័យមុន ឪពុកម្តាយបងធ្លាប់ទូន្មានប្រៀនប្រដៅបងអីខ្លះដែរ?
ខ៖ អឹម...ម៉ែខ្ញុំមិនប្រដែរប្រដៅខ្ញុំផង មានតែយាយ។
ក៖ អញ្ចឹង! គាត់ប្រាប់បងថាម៉េចទៅ?
ខ៖ គាត់ថាចេះជួយយកអាសារគេ អាណិតគេចឹង គាត់ប្រដៅអោយធ្វើល្អអីចឹង
កុំអោយថាពេលឃើញគេពេប ដើរចេញអីស្ទុះខ្ជើមស្ពោះទឹកមាត់អី
គាត់អត់ប្រដែរប្រដៅពាក្យចឹងទេ ព្រោះអីផ្ទះនៅស្រុកខ្ញុំហ្ន៏ គេសុំទៅនៅស្នាក់
ដូចថាសុំទៅនៅស្នាក់អីចឹងហ្នា ដូចថាគេធ្លាប់ស្គាល់ ខ្ញុំនៅពីតូចៗចឹង
ដូចថាអ្នកគេទៅស៊ីឈ្នួលច្រូតមួយចឹងហ្នា ហើយចឹងទៅគេទៅលក់ ឥវ៉ាន់
លក់ខោអាវ ម៉ុងកន្ទេលអី ដល់ស្រុកខ្ញុំចឹងទៅ
យើងដូចថាបាយមួបអីយើងអត់មាន អោយគេទេ តែកន្លែងស្នាក់នៅមាន។
ក៖ ហឹម!
ខ៖ ហ្ន៏ងហើយ!
ក៖ ចាស! ប៉ុណ្ណឹងទេបងហ៎?
ខ៖ ចាស!
ក៖ ហើយទៅឥឡូវ សម័យឥឡូវបងទូន្មានកូនបងថាម៉េចដែរ?
ខ៖ ខ្ញុំប្រាប់វាចឹងដែរ ខ្ញុំថា៖ "កូនអើយ! ដូចថាអ្ហូនសុំអីចឹង
កុំរៀនចិត្តអាក្រក់ពេក ឃ្ហូនវាតូច។" ចេះតែណែនាំ
ចឹងទៅកុំអោយក្មេងៗវាឈ្លោះគ្នាចឹង យើងចេះតែថា ហ្ន៏ងហើយ
ក្មេងវាចេះតែតែ...ហើយក្មេងវានិយាយចំៗ ហើយវាអត់ខ្លាចទេ យើង
នឹកឃើញថានិយាយចំៗទៅវាដូចថាម៉ែឪគេស្តីអោយចេះចុះ
យើងនឹកឃើញក្នុងផ្ទះក្បែរគ្នា វាពិបាកមើលមុខគ្នាចឹងហ្នា។
ក៖ ចឹង!
ខ៖ ហ្ន៏ងហើយ! គេថ្លៃ យើងក៏ថ្លៃដែរចឹង
ក៖ ចាស!
ខ៖ ដូចថាយប់ឡើងចឹងទៅ ដូចថាដេកជាមួយកូនជុំគ្នា កូនចឹង
តែចេះតែដឹកនាំកូនល្អចឹងទៅថា៖ "យើងឃើញគេចឹង កូនកុំសើចកុំមើលងាយ
គេ។" អីចឹង ចេះតែប្រាប់កូនចឹងទៅណ៎ា។
ក៖ ចាស!
ខ៖ រួចខ្ញុំថា៖ "កូនអើយ! យើងរស់មួយជីវិត កុំលំបាកពេកកូនអើយ។"
ឥឡូវហ្ន៏ងប្តីខ្ញុំជាមួយនិងខ្ញុំឥឡូវ គេរវល់ទៅវត្តទៅវ៉ាទៅបុណ្យឥឡូវទៅហើយ
ទៅណាក៏ទៅដែរអោយតែគេហៅទៅបិណ្ឌ ទៅវត្តអីចឹង ទៅហើយ។

ក៖ ហឹម!
ខ៖ ធ្វើបុណ្យហើយ អត់មានគិតអីនោះទេ ចេះតែទៅហើយ។
ក៖ ចាស! ហើយបងជីវិតបងកាលនៅក្មេង កាលណុងបងចូលចិត្តអីដែរ?
ដូចជាការលេងល្បែង កុមារក្មេងៗអី?
ខ៖ អឹម! កាលណុងក្មេងៗចេះតែហក់កៅស៊ូ អោយថាមកពីដើរណាចឹង
ទៅរត់ទៅផ្ទះគេចឹងទៅលេងហក់កៅស៊ូជាមួយគេចឹង
យាយគាត់ចេះតែដេរអីចឹងហ្នា គាត់ថាធំហើយ ចេះតែទៅលេងអី។
ក៖ ចាស! ហើយទៅមុខមួយបអីដែលបងបានចូលចិត្តពិសារដែរ?
ខ៖ ព្រោះអីនៅស្រុកខ្ញុំ យាយខ្ញុំគាត់ធ្វើមួយបន្ទាញ់ដូចជាខ ស្លមួរអីចឹង គាត់
ធ្វើន្ទាញ់ចឹង ពេលខ្ញុំ មកស្រុកខ្មែរចឹង ខ្ញុំចេះតែធ្វើតាមគាត់ ចឹងដែរទៅ។
ក៖ អូ! ខ ម្ហូរអី គាត់ចូលចិត្ត?
ខ៖ ចាសៗ!
ក៖ ចុះនៅកម្ពុជាក្រោម...
ខ៖ ប្រហុកមាំអីអត់តម អត់អីទេ។
ក៖ អូ! ហើយកាលណុងដូចថាបងរៀនមួយបអីហ្នឹងតាមរយ:ពួកគាត់ទៅណ៎?
ខ៖ គាត់ដូចថាពេលដាំបាយដាំអីចឹងគាត់ចេះតែណែនាំចឹង ន៏!
តែពីមុនតាខ្ញុំគាត់ចេះតែណែនាំដែរ ដាំបាយអោយដាំបាយជាត់
ដាំបាយគេអាឡែងអុសនោះ ហើយពីមុនៗ
ស្រុករបស់ខ្ញុំមិនមានចង្ក្រានហ្គាសចង្ក្រានអីមកពីណា ដាំសុទ្ធតែបាយ
ចង្ក្រានអុសហ្នឹង ដាំចឹងទៅចោលខ្លះណាពុះជាត់ទៅយកទឹកបាយ
នាំគ្នាហ៊ីចចឹងទៅ ដាក់ស្ករ នាំគ្នាផឹងចឹងទៅ។
ក៖ ចាស! ហើយទៅមុខមួយបអីដែលបងរបៀបថា
ចាប់អារម្មណ៍ជាងគេហើយបងធ្វើន្ទាញ់ជាងគេ?
ខ៖ អាចចៀនប៉េងប៉ោះ ក្រីឡាបយ៉ា យើងប៉ោះដាក់ចូលនោះ។
ក៖ ចាស!
ខ៖ គេហៅថាដូចចៀនជួនជាមួយប៉េងប៉ោះនោះ។
ក៖ ចាស! មួយហ្នឹងទេបង?
ខ៖ ចាសហើយនឹងខត្រី! ចូលចិត្តខចឹង ទិញត្រសក់ហើយ
ស្ពៃយកមកច្រលក់ចឹងហ្នា ខ្ញុំដាក់អំពិលទុំអីចឹង។
ក៖ ចាស! ចុះបទចម្រៀងវិញ្ញ បងចូលចិត្តស្តាប់អត់?
ខ៖ ចូលចិត្តតើ! ចូលចិត្តបន្ទិចបន្ទួចអីចឹង ចេះតែ...នៅ
ស្រុកវៀតណាមស្តាប់ទៅអត់ដឹងថា ម៉េចដែរ ចេះតែស្តាប់ៗចឹងទៅ តែខ្ញុំរាល់
ថ្ងៃនៅផ្ទះមិនសូវស្តាប់ចម្រៀងអីស្អីនោះទេ។ ពីមុនមានទូរទស្សន៍ខ្សែកាបអីចឹង
ដល់ហើយទៅយើងថាគេទារថ្លៃពេកទៅ យើងខ្ជិលតែម្តងទៅ
ដូចថាមើលវាក្ខានអីអត់ងងុយយប់ឡើង ហើយអស់ភ្លើងចឹងទៅទៀត ហើយខ្ជិល
យកកម្លាំងដេកទៅ ដល់ទទួលចៃដន្យអីទូរទស្សន៍វាខូច យើងមិនបាច់មើល
ផ្តាច់ចោលតែម្តងទៅ។ វាធ្ងរពីមុនហ្គាសលុយទឹកលុយភ្លើងអី ១០ម៉ឺនហ្នា
ហើយឥឡូវវាដូចធ្ងរដែរ វានៅតែ៦ម៉ឺនទៅ៧ម៉ឺន៨ម៉ឺនអីចឹង។
ក៖ ចាស! កាត់បន្ថយការចំណាយបានខ្លះដែរ។
ខ៖ ចាស!
ក៖ ចាសទៅបង ដូចជាបទចម្រៀងដែលបងបានស្តាប់កាលពីមុន បងនៅចាំទេ
? បទចំណងជើងអីខ្លះដែរ?
ខ៖ ខ្ញុំចេះតែស្តាប់ទៅ ច្រើនពេកមិនដឹងស្អីៗទេ ចេះតែ...
ក៖ ហឹម! តែបងមានចូលចិត្តមួយណាដែលធ្វើអោយបងចូលចិត្តចាំដល់ឥឡូវទេ?
ខ៖ ទេ! កាលពីដើមចឹងឃើញគេច្រៀងអាបទ...ចូលចិត្តបទប្រុសៗ
គេច្រៀងអីចឹងហ្នា។

ក៏ ចាស! ហើយសម្រាប់សម័យឥឡូវ ដូចជាបងមានរឿងអីដែលធ្វើអោយបងសប្បាយចិត្តនឹកឃើញបងរំកើបមានមោទនភាពចំពោះខ្លួនឯង ហើយធ្វើងអោយបងសប្បាយចិត្តមានទេ?
ខ៏ ខ្ញុំទៅដល់ផ្ទះចឹង ខ្ញុំចេះតែមួលម៉ៅចឹង ដោយសារកូនៗនិយាយហៅវាអោយធ្វើនេះ ទៅធ្វើនោះចឹង វាអត់ដូចចិត្តចឹង ចេះតែខឹងចឹង ប៉ាវាចេះតែស្តីអោយខ្ញុំ។
ក៏ ចាស! តែមានរឿងណាដែលបានធ្វើអោយបងបានសប្បាយចិត្តទេបង?
ខ៏ ខ្ញុំអត់កើតអីផង។
ក៏ ចាស! អញ្ជឹងជាចុងក្រោយ
បងមានពាក្យពេចន៍អីដើម្បីផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយអ្នកដែលបានស្តាប់?
ខ៏ មិនដឹងគ្រាន់ថា មិនដឹងនិយាយយ៉ាងម៉េច ខ្ញុំមិនសូវចេះនិយាយផង។
ក៏ និយាយអ៊ីដែលជាពិត អ្វីដែលបងចង់ប្រាប់គេទៅបានហើយ។
ខ៏ គ្រាន់ថា ដូចថាអោយក្មេងៗចឹងហ្នា ខំប្រឹងតស៊ូទៅ ជីវិតទៅមុខ
មិនមែនជីវិតទៅក្រោយទេ។ ចឹងបានថាក្មេងខ្លះ ក្នាអត់ដឹងអីទេ។
ពេលខ្លះទៅគ្នាដឹងទៅ...នៅដឹងថាសង្គមយើងវាយ៉ាងម៉េច ហើយក្មេងខ្លះអត់ដឹងទៅចេះតែតាមគេតាមឯងអីចឹងទៅ អស់ហើយទឹកដីអីចឹងហ្នា។
ក៏ ចាស! ចឹងបងមានតែប៉ុណ្ណឹងទេបងណ៎?
ខ៏ ចាស!
ក៏ ចឹងអរគុណ
ជ្រើនសម្រាប់ថ្ងៃនេះដែលបងបានចំណាយពេលក្នុងការសម្ភាសចឹង បើសិនជាខាងសាលBYU នៅខាងសហរដ្ឋអាមេរិក
គេចង់ដាក់សម្លេងបងដើម្បីទុកអោយកូនចៅជំនាន់ក្រោយ
គេចូលទៅស្តាប់បងនៅក្នុងរបៃសាយរបស់ខាងសាលា តើបងអនុញ្ញាតទេបង?
ទាំងរូបបងដែរហ្នា?
ខ៏ អាហ្នឹងខ្ញុំខ្លាច ពេលដូចថាខ្ញុំអត់ហ៊ានធានា អត់ហានអូខេ ។ ខ្ញុំខ្លាចថាពេលណាទៅរកខ្ញុំអី ពេលណាខ្ញុំទៅស្រុកអីចឹង។
ក៏ រកបងអត់ឃើញមែន?
ខ៏ ហ្នឹងហើយ!
ក៏ អត់អីទេ យើងមានលេខទូរស័ព្ទ បងប្រើលេខទូរស័ព្ទតើហេស?
ខ៏ ខ្ញុំប្រើលេខទូរស័ព្ទ។
ក៏ តើបងមានលេខប៉ុន្ថានដែរ?
ខ៏ ០៧០ ៤០ ៦៤ ៣២ អាហ្នឹងប្រើជាង១០ឆ្នាំហើយ អត់ដូរទៅណាទាំងអស់។
ក៏ ចាស! ចឹងបើថាម៉េចៗខ្ញុំទាក់ទងទៅខាងលេខបងហ្នាណ៎?
ខ៏ ចាស!
ក៏ ចឹងបងអនុញ្ញាតដើម្បីអោយគេដាក់សម្លេងបង
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ដែរឬទេបង?
ខ៏ ចាសៗ!